27 កុម្ភៈ 2017



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២២១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជាជាសហគ្រាសសាធារណៈមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៩ និងមាត្រា១០ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជាជាសហគ្រាសសាធារណៈមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**មាត្រា ១.-**

តែងតាំងក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា សម្រាប់អាណត្តិទី៥ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ខុច មករា** | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ប្រធាន |
| ២-ឯកឧត្តម **ភីមរ័ត្ន ចិសិដ្ឋ** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | |
|---|---|---|
| ៣ -ឯកឧត្តម **ជា ចុះធណា** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤ -ឯកឧត្តម **សន ទី** | អគ្គនាយកនៃទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៥ -តំណាងនិយោជិត | ទូរគមនាគមន៍កម្ពុជា ០១រូប | សមាជិក |

**មាត្រា ២._**

សមាសភាពក្រុមប្រឹក្សាភិបាលដូចមានចែងក្នុងមាត្រា១ ត្រូវបានតែងតាំងសម្រាប់រយៈពេល០៣(បី)ឆ្នាំ អាណត្តិនេះអាចបន្តជាថ្មីទៀតបាន ។

**មាត្រា ៣._**

មុខងាររបស់ក្រុមប្រឹក្សាភិបាល ត្រូវបានបញ្ជាក់បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ដែលបានពិភាក្សាសម្រេចលើគណនីនៃការិយបរិច្ឆេទទី៣ របស់ទូរគមនាគមន៍កម្ពុជា ។ សមាជិកក្រុមប្រឹក្សាភិបាលអាចត្រូវផ្លាស់ប្ដូរដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាមី ។

**មាត្រា ៤._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ